ផែនទីសំណួរ

ជំពូកទី១ ប្រវត្តិសាស្ត្រប្រទេសកម្ពុជាក្នុងបរិបទសង្គ្រាម

មេរៀនទី១ សង្គមរាស្ត្រនិយម

១-ការបង្កើតរបបសង្គមរាស្ត្រនិយម

១-ហេតុអ្វីបានជាព្រះបាទ នរោត្តម សីហនុ ដាក់រាជថ្វាយព្រះបិតា?

២-តើសង្គមរាស្ត្រនិយមជាអ្វី? បង្កើតដោយអ្នកណា? នៅថ្ងៃខែឆ្នាំណា? មានគោលបំណងអ្វីខ្លះ?

៣-តើចលនាសង្គមរាស្ត្រនិយមមានទិសដៅដូចម្តេចខ្លះ?

៤-តើមានកត្តាអ្វីខ្លះធ្វើឱ្យអង្គការសង្គមរាស្ត្រនិយមទទួលបានការគាំទ្រពីប្រជាជន?

៥-តើការបោះឆ្នោតនៅថ្ងៃទី១១ កញ្ញា ឆ្នាំ១៩៥៥ ចលនាសង្គមរាស្ត្រនិយមទទួលបានលទ្ធផលដូចម្តេច?

៦-តើគណបក្សផ្សេងក្រៅពីគណបក្សសង្គមរាស្ត្រនិយមទទួលបានសន្លឹកឆ្នោតដូចម្តេច?

២-សមាជជាតិ

១-ចូរពណ៌នាពីសមាជជាតិក្នុងរបបសង្គមរាស្ត្រនិយម។

២-តើសមាជជាតិលើកចុងក្រោយមានការប៉ះទង្គិចមតិគ្នាដូចម្តេច?

៣-នយោបាយអព្យាក្រឹត

១-ចូរពណ៌នាពីនយោបាយអព្យាក្រឹតក្នុងរបបសង្គមរាស្ត្រនិយម។

២-ចូរអធិប្បាយពីគោលនយោបាយ «អព្យាក្រឹត» នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ ជំនាន់សង្គមរាស្ត្រនិយមរបស់សម្តេចព្រះ នរោត្តម សីហនុ។

៣-ហេតុអ្វីបាជានយោបាយអព្យាក្រឹតកម្ពុជា ងាកទៅរកកុម្មុយនីស្តនៅចុងសម័យសង្គមរាស្ត្រនិយម?

៤-តើនយោបាយអព្យាក្រឹតមានការវិវត្តប៉ុន្មានដំណាក់កាល? អ្វីខ្លះ? ចូររៀបរាប់។

៤-បញ្ហារាជបល្ល័ង្កតំណែងប្រមុខរដ្ឋឆ្នាំ១៩៦០

១-តើការប្រជុំក្រុមប្រឹក្សារាជសម្បត្តិថ្ងៃទី៦ មេសា ១៩៦០ មានអ្នកណាខ្លះ?

២-ហេតុអ្វីបានជានៅឆ្នាំ១៩៦០ គេបង្កើតក្រុមប្រឹក្សារាជានុសិទ្ធិ? មានតួនាទីអ្វី?

៣-ហេតុដូចម្តេចបានជាមានការតែងតាំងសម្តេចព្រះនរោត្តម សីហនុ ជាប្រមុខរដ្ឋនៅឆ្នាំ១៩៦០?

៤-ចូររៀបរាប់ពីការធ្វើប្រជាមតិនៅឆ្នាំ១៩៦០។

៥-សមិទ្ធផលសង្គមរាស្ត្រនិយម

១-ចូររៀបរាប់អំពីសមិទ្ធផលសង្គមរាស្ត្រនិយម។

២-ហេតុអ្វីបានជាគេថា ប្រទេសកម្ពុជានាសម័យសង្គមរាស្ត្រនិយមគឺជាកោះសន្តិភាព?

មេរៀនទី២ សាធារណរដ្ឋខ្មែរ

១-ការលេចឡើងនៃរបបសាធារណរដ្ឋខ្មែរ

១-ចូររៀបរាប់ឈ្មោះមេដឹកនាំសំខាន់ៗនៅសម័យសាធារណរដ្ឋខ្មែរ។

២-តើមុនរដ្ឋប្រហារព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ និងសហសេវិកបានធ្វើសកម្មភាពអ្វីខ្លះ?

៣-ហេតុដូចម្តេចបានជាលេចឡើងនូវរបបសាធារណរដ្ឋខ្មែរ?

៤-ហេតុអ្វីបានជាមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០? ផ្តល់ផលវិបាកអ្វីខ្លះ?

៥-តើពាក្យថា រដ្ឋប្រហារ មានន័យដូចម្តេច? ហេតុអ្វីបានជាគេចាត់ទុកព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ជាការធ្វើរដ្ឋប្រហារ?

៦-តើមានមតិដូចម្តេចខ្លះចំពោះព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០?

៧-តើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រព្រឹត្តឡើងដូចម្តេច?

៨-ក្រោយពីបានឡើងកាន់អំណាច តើរបបសាធារណរដ្ឋខ្មែរបានរៀបចំគោលនយោបាយដូចម្តេចខ្លះ?

៩-មានមតិមួយពោលថា៖ ព្រឹត្តិការណ៍ថ្ងៃទី១៨ មីនា ១៩៧០ ជាការផ្ទេរពីដំណាក់កាលសន្តិភាព ចូលដំណាក់កាលសង្គ្រាម។ ចូរពន្យល់។

១០-ហេតុអ្វីបានជារបបសាធារណរដ្ឋខ្មែរមានការផ្លាស់ប្តូរគណៈរដ្ឋមន្ត្រីញឹកញាប់?

២-សង្គមសេដ្ឋកិច្ចសម័យសាធារណរដ្ឋខ្មែរ

១-តើការទម្លាក់គ្រាប់បែករបស់អាម៉េរិកពីថ្ងៃទី៦ កុម្ភៈ-១៥ សីហា ១៩៧៣ នាំមកនូវផលវិបាកអ្វីខ្លះ?

២-តើនៅក្នុងរបបសាធារណរដ្ឋខ្មែរប្រជាជនកម្ពុជារស់នៅក្នុងស្ថានភាពដូចម្តេច?

៣-តើសេដ្ឋកិច្ចសម័យសាធារណរដ្ឋខ្មែរមានស្ថានភាពដូចម្តេច?

៤-តើមានកត្តាអ្វីខ្លះដែលនាំឱ្យសហរដ្ឋអាម៉េរិកបោះបង់របបសាធារណរដ្ឋខ្មែរចោល?

៣-សង្គ្រាមឆ្នាំ១៩៧០-១៩៧៥

៥-តើមានមូលហេតុអ្វីខ្លះ បណ្តាលឱ្យមានសង្គ្រាមស៊ីវិល(១៩៧០-១៩៧៥)?

៦-តើសង្គ្រាមត្រជាក់បានជះឥទ្ធិពលដូចម្តេចចំពោះកម្ពុជាពីឆ្នាំ១៩៧០-១៩៧៥?

៧-តើត្រូវធ្វើដូចម្តេច ដើម្បីទប់ស្កាត់កុំឱ្យមានសង្គ្រាមស៊ីវិលកើតឡើងនៅកម្ពុជា?

៤-ការដួលរលំរបបសាធារណរដ្ឋខ្មែរ

១-តើមូលហេតុអ្វីខ្លះដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរដួលរលំ?

៥-ការខូចខាតដោយសារសង្គ្រាម និងផលវិបាក

១-តើសង្គ្រាមឆ្នាំ១៩៧០-១៩៧៥ នាំមកនូវផលវិបាកអ្វីខ្លះ?

មេរៀនទី៣ កម្ពុជាប្រជាធិបតេយ្យ

១-រចនាសម្ព័ន្ធដឹកនាំ

១-តើពាក្យខ្មែរក្រហមមានន័យដូចម្តេច?

២-តើពួកខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃខែឆ្នាំណា? ពួកគេបានធ្វើអ្វីខ្លះមកលើប្រជាជននៅទីនោះ?

៣-តើមានកត្តាអ្វីខ្លះជំរុញឱ្យពួកខ្មែរក្រហមអាចឡើងកាន់អំណាចបាន?

៤-តើពួកខ្មែរក្រហមបានប្រើលេសដូចម្តេច ដើម្បីឱ្យប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ?
៥-តើអ្វីជាមូលហេតុពិតនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?
៦-តើការជម្លៀសប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានប៉ុន្មានដំណាក់កាល? អ្វីខ្លះ?
៧-តើប្រវត្តិវិទូភាគច្រើនយល់ឃើញយ៉ាងដូចម្តេច ចំពោះហេតុផលនៃការជម្លៀសរវាងឆ្នាំ១៩៧៥-១៩៧៦?
៨-តើខ្មែរក្រហមមានគោលការណ៍ប៉ុន្មានចំណុច? អ្វីខ្លះ?
៩-តើពាក្យ«អង្គការ»នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានន័យដូចម្តេច?
១០-ចូររៀបរាប់ពីរចនាសម្ព័ន្ធដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ១៩៧៦-១៩៧៨។
១១-ចូររៀបរាប់ពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។
១២-ចូររៀបរាប់ពីរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។
១៣-តើបក្សកុម្មុយនីស្តកម្ពុជា បានបែងចែកតំបន់រដ្ឋបាលដូចម្តេច?
១៤-ចូររៀបរាប់ឈ្មោះមេដឹកនាំតាមភូមិភាគនីមួយៗ។
១៥-តើភូមិភាគណាដែលទទួលប្រជាជនជម្លៀសច្រើនជាងគេ? ព្រោះអ្វី? ប្រជាជនទាំងនោះរស់ក្នុងស្ថានភាពដូចម្តេច?

២-នយោបាយមហាលោតផ្លោះមហាអស្ចារ្យ

១-ចូររៀបរាប់ពីគម្រោងផែនការ៤ឆ្នាំ(១៩៧៧-១៩៨០)របស់បក្សកុម្មុយនីស្តកម្ពុជា?
២-ចូររៀបរាប់ពីជីវភាពរស់នៅរបស់ប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។
៣-តើរបបកម្ពុជាប្រជាធិបតេយ្យបាននាំចេញនិងនាំចូលនូវផលិតផលអ្វីខ្លះ?
៤-តើកម្ពុជាប្រជាធិបតេយ្យ ធ្វើទំនាក់ទំនងការទូតជាមួយប្រទេសណាខ្លះ? មានចំណងមិត្តភាពល្អជាមួយប្រទេសណាខ្លះ?

៥-តើរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យបានចែងដូចម្តេចខ្លះ អំពីសិទ្ធិនិងករណីកិច្ចរបស់ប្រជាជនកម្ពុជាម្នាក់ៗ?

៦-តើរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យបានចែងដូចម្តេចខ្លះ អំពីសិទ្ធិខាងជំនឿ និងសាសនា?

៣-សោកនាដកម្ម

១-តើការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកដូចម្តេច?

២-តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានបង្ខំឱ្យប្រជាជនធ្វើការជាទម្ងន់ដូចម្តេចខ្លះ?

៣-ចូររៀបរាប់ពីការសម្រិតសម្រាំង និងការសម្លាប់រង្គាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៤-ដូចម្តេចដែលហៅថា គុកឥតជញ្ជាំង?

៥-ចូររៀបរាប់ពីមន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៦-ចូររៀបរាប់ពីមន្ទីរស-២១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៧-តើអ្នកទោសនៅក្នុងមន្ទីរស-២១ មានស្ថានភាពដូចម្តេច?

៨-ចូររៀបរាប់ពីវិធីសាស្ត្រសួរចម្លើយក្នុងមន្ទីរស-២១។

៩-ចូររៀបរាប់ពីថ្នាក់ដឹកនាំនៅមន្ទីរស-២១។

១០-ចូររៀបរាប់ពីរចនាសម្ព័ន្ធចាត់តាំងនៅក្នុងមន្ទីរស-២១។

១១-ដូចម្តេចដែលហៅថាខ្មាំងអង្គការ?

១២-តើខ្មែរក្រហមបានបែងចែកសត្រូវជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

១៣-ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្ស?

១៤-តើរបបកម្ពុជាប្រជាធិបតេយ្យបានរំលោភបំពានលើសិទ្ធិកុមារយ៉ាងដូចម្តេច?

១៥-តើសិល្បៈ និងចម្រៀងសម័យកម្ពុជាប្រជាធិបតេយ្យគេបង្កើតឡើងដើម្បីអ្វី? ចម្រៀងទាំងនោះមានបទអ្វីខ្លះ?

១៦-តើវិស័យសុខាភិបាលនៅសម័យកម្ពុជាប្រជាធិបតេយ្យមានស្ថានភាពដូចម្តេច?

១៧-ហេតុអ្វីបានជាពួកខ្មែរក្រហមធ្វើបដិវត្តន៍?

៤-ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

១-ហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យមានរយៈពេលខ្លី?

២-មូលហេតុអ្វីខ្លះដែលធ្វើឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ?

៥-ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម

១-តើសាលាក្តីខ្មែរក្រហមបង្កើតឡើងនៅឆ្នាំណា? ក្នុងគោលបំណងអ្វីខ្លះ?

២-ហេតុអ្វីបានជាត្រូវកាត់ទោសមេដឹកនាំខ្មែរក្រហម?

៣-តើសាលាក្តីខ្មែរក្រហមមានបេសកកម្មអ្វីខ្លះ?

៤-តើមេដឹកនាំខ្មែរក្រហមរូបណាខ្លះ ដែលត្រូវបាននាំខ្លួនមកកាត់ទោស?

៥-តើមន្ត្រីជាន់ខ្ពស់របស់របបសាធារណរដ្ឋខ្មែររូបណាខ្លះ ដែលត្រូវខ្មែរក្រហមកាត់ទោសប្រហារជីវិត?

មេរៀនទី៤ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (១៩៧៩-១៩៩៣)

១-ការរំដោះប្រទេសកម្ពុជាពីរបបកម្ពុជាប្រជាធិបតេយ្យ

១-ចូររៀបរាប់ពីកំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។

២-តើមូលហេតុអ្វីខ្លះបានជាបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា?

៣-ចូរពណ៌នាពីកត្តាសំខាន់ៗដែលនាំឱ្យមានជ័យជម្នះលើរបបប្រល័យពូជសាសន៍នៅថ្ងៃទី៧ មករា ១៩៧៩។

៤-តើជ័យជម្នះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មានគុណតម្លៃជាប្រវត្តិសាស្ត្រដូចម្តេចខ្លះ?

២-សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)

១-តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រកាន់យកនយោបាយបែបណា?

២-តើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានអង្គការគ្រប់គ្រងកំពូលសំខាន់ៗប៉ុន្មាន? អ្វីខ្លះ? ចូររៀបរាប់

៣-តើរដ្ឋអំណាចខ្មែរក្នុងដំណាក់កាលដំបូងក្រសួងសំខាន់ៗកាន់កាប់ដោយមនុស្សក្រុមណាខ្លះ?

៤-ហេតុអ្វីបានជាមានវត្តមានជំនាញការ និងកងទ័ពវៀតណាមនៅពាសពេញផ្ទៃប្រទេសកម្ពុជាក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩?

៣-ការកសាងសន្តិភាព និងការកសាងជាតិឡើងវិញ

១-តើនៅក្រោយថ្ងៃរំដោះថ្ងៃទី៧ មករា ១៩៧៩ កម្ពុជាទទួលបានសន្តិភាព និងឯកភាពបូរណភាពទឹកដីឬនៅ? ព្រោះអ្វី?

២-តើប្រទេសកម្ពុជាក្រោយពីរំដោះចេញពីរបបកម្ពុជាប្រជាធិបតេយ្យបានបែកខ្ញែកជាប៉ុន្មានភាគី? អ្វីខ្លះ? ចូររៀបរាប់

៣-ដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ តើរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាត់វិធានការដូចម្តេចខ្លះ?

៤-ចូររៀបរាប់ពីផែនការ ក-៥។

៤-ការកសាងជាតិឡើងវិញ

១-តើសង្គមកម្ពុជាក្រោយថ្ងៃរំដោះមានស្ថានភាពដូចម្តេចខ្លះ?

២-តើមហាសន្និបាតបក្សលើកទី៤(១៩៨១) និងលើកទី៥(១៩៨៥) រដ្ឋាភិបាលបានដាក់ចេញនូវគោលការណ៍អ្វី? មានសមាសភាពអ្វីខ្លះ?

៣-តើមុខព្រួញសេដ្ឋកិច្ចទាំង៨របស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាមានអ្វីខ្លះ? ចូររៀបរាប់។

៤-ចូររៀបរាប់ពីការស្តារប្រទេសក្រោយឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩។

៥-តើនៅឆ្នាំ១៩៧៩ សហភាពសូវៀតបានផ្តល់ជំនួយឥតសំណងដល់កម្ពុជាមានអ្វីខ្លះ?

៦-តើមានព្រឹត្តិការណ៍អន្តរជាតិអ្វីខ្លះ ដែលផ្តល់បច្ច័យល្អដល់កម្ពុជាក្នុងការចរចាសន្តិភាព?

៧-ដើម្បីបង្រួបបង្រួមជាតិកម្ពុជា តើគេបានបង្កើតឱ្យមានកិច្ចចរចាសំខាន់ៗប៉ុន្មានលើក? ចូររៀបរាប់។

៨-តើការចរចានៅថ្ងៃទី២៤ កក្កដា ១៩៨៨ របស់ខ្មែរទាំង៤ភាគីទទួលបានលទ្ធផលដូចម្តេច?

៩-ចូរពណ៌នាពីការខិតខំចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជានាទសវត្សឆ្នាំ១៩៨០-១៩៩០។

១០-តើការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅថ្ងៃទី២៩-៣០ មេសា ឆ្នាំ១៩៨៩ បានផ្លាស់ប្តូរអ្វីខ្លះ?

១១-តើមានប្រទេសណាខ្លះដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

១២-តើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ផ្តោតទៅលើចំណុច និងមានខ្លឹមសារសំខាន់ៗអ្វីខ្លះ?

១៣-តើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី ២៣ តុលា ១៩៩១មានសារៈសំខាន់ដូចម្តេចខ្លះ?

១៤-ចូររៀបរាប់ពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា

១៥-តើប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញនៅឆ្នាំណា? ព្រោះអ្វី?

១៦-ហេតុអ្វីបានជាគេចាត់ទុកថាសម្តេចព្រះនរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ជាបិតាសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជា?

មេរៀនទី៥ ព្រះរាជាណាចក្រកម្ពុជាទី២

១-របបត្រប់ត្រងថ្មី

១-តើការបោះឆ្នោតនៅកម្ពុជា(១៩៩៣-២០២៣)មានប៉ុន្មានអាណត្តិ?

២-តើការបោះឆ្នោតថ្ងៃទី២៣-២៨ ឧសភា ១៩៩៣ ទទួលបានលទ្ធផលដូចម្តេច?

៣-ចូរបង្ហាញពីការកកើតឡើងនៃរដ្ឋាភិបាលថ្មីនៃព្រះរាជាណាចក្រកម្ពុជាទី២?

២-ការកសាងសន្តិភាព

១-ហេតុអ្វីបានជាកម្ពុជាចាប់ពីឆ្នាំ១៩៩៣-១៩៩៨ មកនៅតែមានអសន្តិសុខ?

២-តើកម្ពុជាបានសន្តិភាពពេញលេញនៅឆ្នាំណា? តើសន្តិភាពពេញលេញនេះនាំមកនូវអ្វីខ្លះ សម្រាប់កម្ពុជា?

៣-តើគោលនយោបាយឈ្នះ ឈ្នះជាអ្វី? តើការអនុវត្តគោលនយោបាយឈ្នះ ឈ្នះ បាននាំអ្វីខ្លះដល់កម្ពុជា?

៤-តើយុទ្ធសាស្ត្រឌីហ្វីដ(DIFID) មានអត្ថន័យដូចម្តេច?

៣-ការអភិវឌ្ឍប្រទេស

១-តើយុទ្ធសាស្ត្រត្រីកោណមានទិសដៅដូចម្តេច? មានមុំសំខាន់ៗអ្វីខ្លះ?

២-តើយុទ្ធសាស្ត្រចតុកោណមានទិសដៅដូចម្តេច? ភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រនេះអាស្រ័យលើអ្វីខ្លះ? មានមុំសំខាន់ៗអ្វីខ្លះ?

៣-តើយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណបានធ្វើឱ្យកម្ពុជាមានការអភិវឌ្ឍដូចម្តេចខ្លះ?

៤-ចូររៀបរាប់ពីយុទ្ធសាស្ត្របញ្ចកោណ។

៥-តើការចូលជាសមាជិកអាស៊ានបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់កម្ពុជា?

៦-តើសម្បត្តិវប្បធម៌ខ្មែរអ្វីខ្លះ ដែលត្រូវបានចុះក្នុងបញ្ជីអង្គការUNESCO?

៧-តើរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ បានកំណត់យកថ្ងៃខែណាជាទិវាសន្តិភាពនៅកម្ពុជា? ដើម្បីអ្វី?

៨-ចូរពណ៌នាពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលពីឆ្នាំ១៩៩៣-បច្ចុប្បន្ន។
៩-មូលហេតុអ្វីបានចាំបាច់មានកិច្ចព្រមព្រៀងព្រំដែន? តើការបោះបង្គោលព្រំដែនរវាងកម្ពុជាជាមួយប្រទេសថៃ ឡាវ វៀតណាម នាំឱ្យកម្ពុជាទទួលបានផលប្រយោជន៍អ្វីខ្លះ?
១០-ចូរបកស្រាយពីតួនាទីនៃ "វប្បធម៌សន្ធនា" នៅក្នុងសង្គមប្រជាធិបតេយ្យ។

ជំពូកទី២ ប្រវត្តិសាស្ត្រតំបន់ក្នុងបរិបទសង្គ្រាមត្រជាក់

មេរៀនទី១ បម្រែបម្រួលសង្គមអាស៊ីអាគ្នេយ៍

១-ការតស៊ូដើម្បីឯករាជ្យជាតិ

១-តើមហាអំណាចអឺរ៉ុបណាខ្លះ ដែលធ្លាប់បានមកដាក់អាណានិគមនៅតំបន់អាស៊ីអាគ្នេយ៍?
២-ក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ តើប្រទេសណាដែលរួចផុតពីនឹមអាណានិគមរបស់ពួកអឺរ៉ុប? ព្រោះអ្វី?
៣-តើចលនាតស៊ូទាមទារឯករាជ្យនៅតំបន់អាស៊ីអាគ្នេយ៍មានប៉ុន្មានបែប? អ្វីខ្លះ?
៤-តើក្រុមណាខ្លះជាកម្លាំងស្នូលនៅក្នុងចលនាតស៊ូ ដើម្បីឯករាជ្យជាតិនៅតំបន់អាស៊ីអាគ្នេយ៍?
៥-តើមានកត្តាអ្វីខ្លះនាំឱ្យប្រទេសនៅអាស៊ីអាគ្នេយ៍តស៊ូទាមទារឯករាជ្យពីអាណានិគមបាន?
៦-មូលហេតុអ្វីបានជាអឺរ៉ុបដាក់អាណានិគមន៍មកលើតំបន់អាស៊ីអាគ្នេយ៍?
៧-ចូររៀបរាប់ពីការប្រែបម្រួលសង្គមនៅអាស៊ីអាគ្នេយ៍ក្នុងសម័យអាណានិគម។

២-អាស៊ីអាគ្នេយ៍នៅសម័យសង្គ្រាមត្រជាក់

១-តើសង្គ្រាមត្រជាក់បានផ្តល់ផលប៉ះពាល់អ្វីខ្លះដល់ប្រជាជាតិនៅអាស៊ីអាគ្នេយ៍?

២-តើសង្គ្រាមត្រជាក់ជះឥទ្ធិពលអ្វីខ្លះដល់បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍?
៣-តើសង្គ្រាមត្រជាក់ក្នុងទសវត្សរ៍ឆ្នាំ១៩៥០-៦០ បាននាំមកនូវអ្វីខ្លះដល់ឧបទ្វីបឥណ្ឌូចិន?
៤-តើអ្វីជាសង្គ្រាមត្រជាក់? សង្គ្រាមត្រជាក់មានផលវិបាកអ្វីខ្លះដល់កម្ពុជា?

៣-អាស៊ីអាគ្នេយ៍ក្រោយសង្គ្រាមត្រជាក់

១-តើក្រោយសង្គ្រាមត្រជាក់បណ្តាប្រទេសអាស៊ីអាគ្នេយ៍មានស្ថានភាពដូចម្តេច?

មេរៀនទី២ ប្រទេសវៀតណាម

១-ដំណាក់កាលតស៊ូដណ្តើមឯករាជ្យពីបារាំង

១-តើប្រទេសបារាំងដាក់អាណានិគមលើប្រទេសវៀតណាមដោយរបៀបណា?
២-ចូររៀបរាប់ពីនយោបាយសេដ្ឋកិច្ចរបស់អាណានិគមបារាំង មកលើប្រទេសវៀតណាមនៅក្រោយសង្គ្រាមលោកលើកទី១។
៣-តើលោក ហូ ជីមិញ ជានរណា? បានធ្វើអ្វីខ្លះសម្រាប់ប្រទេសវៀតណាម?
៤-តើមានកត្តាអ្វីខ្លះបណ្តាលឱ្យបារាំងព្រមប្រគល់ឯករាជ្យឱ្យដល់វៀតណាម?

២-ដំណាក់កាលសង្គ្រាមប្រឆាំងនឹងសហរដ្ឋអាម៉េរិក

១-តើមូលហេតុអ្វីខ្លះនាំឱ្យមានសង្គ្រាមវៀតណាមផ្ទុះឡើង? សង្គ្រាមនេះផ្តល់ផលវិបាកអ្វីខ្លះ?
២-តើប្រទេសនីមួយៗដែលបានប្រឡូកចូលក្នុងសង្គ្រាមវៀតណាម ធ្វើឡើងក្នុងគោលបំណងអ្វី?
៣-ចូរពណ៌នាពីដំណើរប្រព្រឹត្តទៅនៃសង្គ្រាមរវាងវៀតណាមខាងជើង និងខាងត្បូង។
៤-តើសង្គ្រាមវៀតណាមទាំងពីរបញ្ចប់ទៅដោយរបៀបណា?

៥-ហេតុដូចម្តេចបានជាកងទ័ពវៀតណាមខាងជើងទទួលជ័យជម្នះលើកងទ័ពវៀតណាមខាងត្បូង និងសហរដ្ឋអាម៉េរិក?

៣-កំណែទម្រង់ដូយម៉ឺយ(Doi moi reform)

១-តើកំណែទម្រង់ដូយម៉ឺយជាអ្វី?

២-តើកំណែទម្រង់ដូយម៉ឺយមានសារៈសំខាន់ដូចម្តេច? ចូរបង្ហាញ។

៣-តើកំណែទម្រង់ដូយម៉ឺយមានគោលការណ៍មូលដ្ឋានអ្វីខ្លះ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចវៀតណាម?

៤-តើកំណែទម្រង់ដូយម៉ឺយបានជះឥទ្ធិពលដូចម្តេចខ្លះដល់កម្ពុជា?

៥-តើប្រទេសវៀតណាមបច្ចុប្បន្នមានអ្វីគួរឱ្យកត់សម្គាល់ខ្លះ?

មេរៀនទី៣ ប្រទេសថៃ

១-កំណើតរបបរាជានិយមធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ

១-តើរាជានិយមថៃសព្វថ្ងៃមានឥទ្ធិពល និងតួនាទីដូចម្តេចខ្លះ?

២-តើចាប់ពីពាក់កណ្តាលស.វទី១៩ សៀមបានធ្វើទំនើបកម្មលើស្ថាប័នណាខ្លះ?

៣-ចូរអធិប្បាយពីការធ្វើកំណែទម្រង់របស់ព្រះចៅ មកុដ និងជូឡាឡុងកន។

៤-តើនិស្សិតសៀមជំនាន់ទី១ ដែលវិលមកពីការសិក្សានៅអឺរ៉ុបបានធ្វើញត្តិស្នើព្រះចៅ ជូឡាឡុងកន ធ្វើអ្វីខ្លះ? ព្រះអង្គយល់ព្រមឬទេ? ព្រោះអ្វី?

៥-ហេតុអ្វីបានជាព្រះចៅ ជូឡាឡុងកន ចាំបាច់ធ្វើកំណែទម្រង់សង្គមថៃ?

៦-តើមូលហេតុអ្វីបានជាផ្ទុះបដិវត្តន៍នៅប្រទេសថៃឆ្នាំ១៩៣២? ព្រឹត្តិការណ៍នេះផ្តល់ផលវិបាកអ្វីខ្លះ?

៧-ហេតុអ្វីបានជាប្រទេស«សៀម» បានប្តូរឈ្មោះទៅជាប្រទេស«ថៃ»នៅឆ្នាំ១៩៣៩?

រៀបរៀងដោយ ឈិន ចណ្ឌី

៨-ចូរបង្ហាញពីលក្ខណៈនៃប្រព័ន្ធសភានិយមថៃនាក្រោយ សង្គ្រាមលោកលើកទី២។

៩-តើក្រោយសង្គ្រាមលោកលើក ទី២ប្រទេសថៃជួបវិបត្តិរដ្ឋប្រហារអ្វីខ្លះ?

១០-ហេតុអ្វីបានជាមានការផ្លាស់ប្តូរពីរបបរាជានិយមផ្តាច់ការមកជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនៅក្នុងប្រទេសថៃ?

២-កំណែទម្រង់នយោបាយ សេដ្ឋកិច្ច និងសង្គម

១-តើព្រះចៅ ភូមិពលអតុល្យតេជ បានធ្វើសកម្មភាពអ្វីខ្លះ ដើម្បីពង្រឹងស្ថាប័នព្រះមហាក្សត្រឡើងវិញ?

២-តើម្ចាស់ក្សត្រី សិរីកិត្តិ៍ បានធ្វើអ្វីខ្លះដើម្បីជួយដល់សង្គមថៃ?

៣-ស្ថានភាពនយោបាយក្រោយរដ្ឋប្រហារឆ្នាំ២០០៦

១-តើរដ្ឋប្រហារឆ្នាំ២០០៦បង្កវិបត្តិអ្វីខ្លះដល់នយោបាយថៃនិងប្រទេសជិតខាង?

២-តើអំណាចយោធាថៃមានតួនាទីអ្វីខ្លះក្នុងប្រទេសថៃ?

៣-ចូរពណ៌នាពីសង្គ្រាមតាមព្រំដែនរវាងកម្ពុជា និងថៃឆ្នាំ២០២៥។

មេរៀនទី៤ ប្រទេសសិង្ហបុរី

១-កំណកំណើតរដ្ឋ

១-ចូររៀបរាប់ពីទីតាំង និងការកកើតប្រទេសសិង្ហបុរី។

២-តើប្រទេសសិង្ហបុរីមានភាសាផ្លូវការប៉ុន្មាន? ភាសាអ្វីខ្លះ?

៣-តើនៅសិង្ហបុរីសាសនាអ្វីខ្លះ?

៤-ហេតុអ្វីបានជានៅឆ្នាំ១៩៣០ សិង្ហបុរីក្លាយជាកំពង់ផែដ៏សំខាន់បំផុតនៅអាស៊ី អាគ្នេយ៍?

២-ស្ថានភាពនយោបាយ

១-ហេតុអ្វីបានជាសិង្ហបុរីផ្តាច់ខ្លួនពីសហព័ន្ធម៉ាឡេស៊ី?

២-តើសិង្ហបុរីជួបបញ្ហាអ្វីខ្លះក្រោយពីផ្តាច់ខ្លួនចេញពីសហព័ន្ធម៉ាឡេស៊ី?
៣-ចូរពន្យល់អំពីនយោបាយដឹកនាំសិង្ហបុរីក្រោមការដឹកនាំរបស់លោក លី ក្វាន់យូ។
៤-តើលោកលី ក្វាន់យូ មានស្នាដៃអ្វីខ្លះសម្រាប់សិង្ហបុរី?
៥-តើនៅពេលលោក ហ្គោ ចុកតុង ក្លាយជានាយករដ្ឋមន្ត្រី លោកបានថ្លែងដូចម្តេច អំពីក្តីបារម្ភរបស់គាត់ចំពោះសិង្ហបុរី?

៣-ស្ថានភាពសេដ្ឋកិច្ច

១-តើសេដ្ឋកិច្ចសិង្ហបុរីពឹងផ្អែកលើវិស័យអ្វីខ្លះ? ចូររៀបរាប់។
២-តើកត្តាអ្វីខ្លះដែលធ្វើឱ្យសិង្ហបុរីក្លាយជាកូននាគនៅអាស៊ី?

មេរៀនទី៥ បណ្តាប្រទេសតំបន់មជ្ឈិមបូព៌ា

១-បញ្ហាចម្រុះជាតិសាសន៍

១-តើនៅតំបន់មជ្ឈិមបូព៌ាមានប្រទេសចំនួនប៉ុន្មាន? អ្វីខ្លះ?
២-តើសាសនានៅប្រទេសស៊ីរីមានតួនាទីអ្វីខ្លះ?
៣-ចូររៀបរាប់ពីការរស់នៅចម្រុះជាតិសាសន៍របស់ប្រជាជនក្នុងប្រទេសអ៊ីរ៉ាក់។
៤-តើនៅឆ្នាំ១៩៧៥ ប្រទេសលីបង់បានជួបបញ្ហាអ្វី? ចូរបង្ហាញ។
៥-ចូរពណ៌នាពីដំណើរជីវិតពួក អ៊ីស្រាអែលក្នុងអំឡុងឆ្នាំ១៩៤៩ និងក្រោយឆ្នាំ១៩៦៧។
៦-តើដំបូងឡើយប្រទេសអារ៉ាប៊ីសាអូឌីត ជាប្រទេសដូចម្តេច? ក្រោយមកប្រែក្លាយទៅជាបែបណា?
៧-តើប្រទេសអង់គ្លេសបានធ្វើដូចម្តេចខ្លះមកលើប្រទេសយេម៉ែន?
៨-តើនៅក្នុងអំឡុងឆ្នាំ១៩០០ ប្រទេសអេហ្ស៊ីបបានជួបបញ្ហាអ្វី? រដ្ឋាភិបាលបានធ្វើដូចម្តេច? ទទួលបានលទ្ធផលបែបណា?

៩-ចូររៀបរាប់ពីបម្រែបម្រួលនយោបាយរបស់ប្រទេសស៊ូដង់ចាប់ពីឆ្នាំ១៨៩៨-១៩៥៦។

១០-តើតំបន់មជ្ឈិមបូព៌ាមានបម្រែបម្រួលនយោបាយ សេដ្ឋកិច្ច និងសង្គមអ្វីខ្លះ?

១១-តើអ្វីខ្លះជាបញ្ហារួមកើតឡើងនៅមជ្ឈិមបូព៌ា?

១២-តើឧបសគ្គក្នុងការអភិវឌ្ឍប្រទេសនៅតំបន់មជ្ឈិមបូព៌ាបណ្តាលមកពីមូលហេតុអ្វី?

២-នយោបាយកំពូលមហាអំណាចដើម្បីគ្រប់គ្រងតំបន់មជ្ឈិមបូព៌ា

១-តើប្រទេសមហាអំណាចណាខ្លះដែលបានដណ្តើមផលប្រយោជន៍គ្នានៅតំបន់មជ្ឈិមបូព៌ា?

២-ហេតុអ្វីបានជាប្រទេសមហាអំណាចដណ្តើមគ្នាគ្រប់គ្រងតំបន់មជ្ឈិមបូព៌ា?

៣-ចូររៀបរាប់ពីការប្រជែងគ្នារបស់មហាអំណាចក្នុងការគ្រប់គ្រងលើតំបន់មជ្ឈិមបូព៌ានៅឆ្នាំ១៩១៩-១៩៣៩។

៤-ចូររៀបរាប់ពីការប្រជែងគ្នារបស់មហាអំណាចក្នុងការគ្រប់គ្រងលើតំបន់មជ្ឈិមបូព៌ាក្រោយឆ្នាំ១៩៤៥រហូតដល់ទសវត្សរ៍ឆ្នាំ១៩៥០។

៥-តើការប្រជែងគ្នារបស់មហាអំណាចក្នុងការគ្រប់គ្រងលើតំបន់មជ្ឈិមបូព៌ានាំមកនូវផលវិបាកអ្វីខ្លះ?

៣-សន្និដ្ឋាន

១-ហេតុអ្វីបានជាមជ្ឈិមបូព៌ាក្លាយជាតំបន់ប្រកាន់សាសនាអ៊ិស្លាម? ចូរពន្យល់

២-តើប្រភពនៃទំនាស់នៅតំបន់មជ្ឈិមបូព៌ាបណ្តាលមកពីកត្តាអ្វីខ្លះ?

មេរៀនទី៦ ប្រទេសអ៊ីស្រាអែល

១-កំណើតរដ្ឋអ៊ីស្រាអែល

១-តើរដ្ឋអ៊ីស្រាអែលត្រូវបានបង្កើតឡើងវិញយ៉ាងដូចម្តេច?

២-ហេតុអ្វីបានជាពិភពអារ៉ាប់មិនសប្បាយចិត្តនឹងការកើតឡើងនៃរដ្ឋអ៊ីស្រាអែល?

២-ការរៀបចំរចនាសម្ព័ន្ធដឹកនាំរដ្ឋ

១-តើប្រធានាធិបតី និងនាយករដ្ឋមន្ត្រីទី១របស់អ៊ីស្រាអែលមានឈ្មោះអ្វីខ្លះ?

២-ចូរគូសរចនាសម្ព័ន្ធដឹកនាំរដ្ឋអ៊ីស្រាអែលក្រោយទទួលបានឯករាជ្យ។

៣-តើក្រោយទទួលបានឯករាជ្យឆ្នាំ១៩៤៨ អ៊ីស្រាអែលបានជួបបញ្ហាអ្វីខ្លះ?

៤-តើមេដឹកនាំអ៊ីស្រាអែលបានរៀបចំផែនការការពារជាតិដូចម្តេច?

៥-តើជនជាតិជ្វីបមានមនសិការជាតិយ៉ាងណាខ្លះ? ចូរពន្យល់។

៣-សង្គ្រាមអ៊ីស្រាអែលនឹងប្រទេសអារ៉ាប«សង្គ្រាមប្រាំមួយថ្ងៃ»

១-តើមានកត្តាអ្វីខ្លះនាំឱ្យមានសង្គ្រាមរវាងអ៊ីស្រាអែល និងប្រទេសអារ៉ាប់?

២-តើសង្គ្រាមប្រាំមួយថ្ងៃរវាងអ៊ីស្រាអែល និងប្រទេសអារ៉ាប់បានកើតឡើងយ៉ាងដូចម្តេច?

៣-តើសង្គ្រាមប្រាំមួយថ្ងៃរវាងពិភពអារ៉ាប់ និងអ៊ីស្រាអែលបានបន្សល់ទុកនូវផលវិបាកអ្វីខ្លះ?

៤-តើមានមូលហេតុអ្វីខ្លះបណ្តាលឱ្យអ៊ីស្រាអែលអាចធ្វើសង្គ្រាមឈ្នះប្រទេសអារ៉ាប់ក្នុងសង្គ្រាមប្រាំមួយថ្ងៃ?

៤-ដំណោះស្រាយនិងបញ្ហាប្រឈម

១-តើអង្គការសហប្រជាជាតិបានចេញសេចក្តីសម្រេចដូចម្តេចខ្លះ ចំពោះដំណោះស្រាយនៃសង្គ្រាមប្រាំមួយថ្ងៃរវាងអ៊ីស្រាអែល និងពិភពអារ៉ាប់។

២-តើប្រទេសអារ៉ាប់និងអ៊ីស្រាអែលមានឥរិយាបថបែបណា ចំពោះសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ?

៣-ប្រទេសអាណានិគមច្រើនទុកបញ្ហាឱ្យប្រទេសក្រោមអាណានិគមរបស់ខ្លួន។ ចូរបង្ហាញ។

៤-ហេតុអ្វីបានជានៅឆ្នាំ២០១៦សហរដ្ឋអាម៉េរិកបានចុះកិច្ចព្រមព្រៀងផ្តល់ជំនួយយោធាដល់អ៊ីស្រាអែលរយៈពេល១០ឆ្នាំ ដែលមានទំហំទឹកប្រាក់ធំបំផុតមួយក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាម៉េរិក?

ជំពូកទី៣ ប្រវត្តិសាស្ត្រពិភពលោកដំណាក់កាលសង្គ្រាមត្រជាក់

មេរៀនទី១ សហរដ្ឋអាម៉េរិក

១-នយោយោបាយ

១-តើសហរដ្ឋអាម៉េរិកបានប្រកាសឯករាជ្យពីអង់គ្លេសនៅថ្ងៃខែឆ្នាំណា?

២-តើសហរដ្ឋអាម៉េរិកបានប្រកាន់យកនយោបាយបែបណា?

៣-ចូររៀបរាប់ពីស្ថាប័ននយោបាយរបស់សហរដ្ឋអាម៉េរិក។

៤-តើនៅសហរដ្ឋអាម៉េរិកមានគណបក្សប៉ុន្មាន? អ្វីខ្លះ? ចូររៀបរាប់។

៥-តើទ្រឹស្តីទ្រូម៉ាន់ជាអ្វី? ដើម្បីអនុវត្តទៅលើទ្រឹស្តីនេះគេត្រូវធ្វើដូចម្តេច?

៦-ហេតុអ្វីបានជាអាម៉េរិកសម្រេចផ្តល់ជំនួយដល់សេដ្ឋកិច្ចអឺរ៉ុប?

៧-តើសករាជព្រំដែនថ្មី (New Frontier) ជាអ្វី? ហើយមានទិសដៅអ្វីខ្លះ?

៨-តើនយោបាយការបរទេសរបស់សហរដ្ឋអាម៉េរិក ក្នុងដំណាក់កាលសង្គ្រាមត្រជាក់ប្រឈមនឹងបញ្ហាអ្វីខ្លះ?

៩-តើក្នុងអាណត្តិរបស់ប្រធានាធិបតីអែសិនហាវ័រ សហរដ្ឋអាម៉េរិកបានជួបនូវបញ្ហាអ្វីខ្លះ?

២-សេដ្ឋកិច្ចអាម៉េរិក

១-តើមូលហេតុអ្វីខ្លះដែលធ្វើឱ្យសហរដ្ឋអាម៉េរិកក្លាយជាមហាអំណាចសេដ្ឋកិច្ចក្រោយសង្គ្រាមលោកលើកទី២?

២-ហេតុអ្វីបានជាសហរដ្ឋអាម៉េរិកពង្រីកឥទ្ធិពលរបស់ខ្លួនទៅលើពិភពលោក?

៣-សង្គមអាម៉េរិក

១-តើសង្គមសហរដ្ឋអាម៉េរិកប្រឈមបញ្ហាដូចម្តេចខ្លះក្រោយសង្គ្រាមលោកលើកទី២?

២-ហេតុអ្វីបានជាចាប់ពីឆ្នាំ១៩៩០ មកសហរដ្ឋអាម៉េរិកមានកំណើនប្រជាជនយ៉ាងខ្លាំង?

៣-ហេតុអ្វីបានជានៅក្រោយសង្គ្រាមលោកលើកទី២ សហរដ្ឋអាម៉េរិកក្លាយជាសង្គមសម្ភារៈនិយម?

មេរៀនទី២ សហភាពសូវៀត

១-នយោបាយ

១-ហេតុអ្វីបានជាប្រជាជនសូវៀតលើកតម្កើងលោកស្តាលីនស្មើនឹងអាទិទេព?

២-តើគេមើលឃើញលើកតម្កើងលោក ស្តាលីន តាមរយៈអ្វីខ្លះ?

៣-តើលោក ស្តាលីន បានពង្រីកអំណាចរបស់គាត់ដោយរបៀបណា?

៤-តើក្រោយពីមរណៈភាពរបស់ លោក ស្តាលីន មានប្រតិកម្មដូចម្តេច?

៥-តើការដឹកនាំរបស់លោក គ្រូតស្ហូវ មានចំណុចខ្លាំង និងចំណុចខ្សោយអ្វីខ្លះ?

៦-ហេតុអ្វីបានជាប្រធានាធិបតីសូវៀតបានផ្លាស់ប្តូរគ្នារយៈពេលខ្លី? ការផ្លាស់ប្តូរបែបនេះនាំឱ្យសូវៀតរីកចម្រើនដែរឬទេ? ព្រោះអ្វី?

៧-តើនៅក្រោយសង្គ្រាមលោកលើទី២ នយោបាយពិភពលោកបានចែកជាប៉ុន្មានប្លុក? អ្វីខ្លះ?

៨-តើសង្គ្រាមលោកលើកទី២ធ្វើឱ្យសហភាពសូវៀតរងនូវវិនាសកម្ម និងការខូចខាតអ្វីខ្លះ?

៩-តើវាំងននដែកជាអ្វី?

១០-តើការបែកបាក់រវាងសហភាពសូវៀត និងចិន បាននាំមកនូវការផ្លាស់ប្តូរនយោបាយដូចម្តេចខ្លះនៅលើពិភពលោក?

១១-តើនយោបាយក្រៅប្រទេសរបស់សហភាពសូវៀត ក្នុងដំណាក់កាលសង្គ្រាមត្រជាក់ ប្រឈមមុខនឹងបញ្ហាអ្វីខ្លះ?

១២-តើមានមូលហេតុណាខ្លះដែលបណ្តាលឱ្យសហភាពសូវៀតក្លាយជាមហាអំណាចថ្មីក្រោយសង្គ្រាមលោកលើកទី២?

១៣-ហេតុអ្វីបានជាក្រោយសង្គ្រាមលោកលើកទី២ ប្រទេសលោកខាងលិចព្រួយបារម្ភចំពោះឥទ្ធិពលចិន?

១៤-តើសូវៀតបានធ្វើអ្វីខ្លះ ដើម្បីទប់ទល់នឹងសហរដ្ឋអាម៉េរិកក្នុងសម័យសង្គ្រាមត្រជាក់?

២-សេដ្ឋកិច្ចក្រោយសង្គ្រាមលោកលើកទី២

១-តើមុនសង្គ្រាមលោកលើកទី២ សូវៀតបានអនុវត្តផែនការ៥ឆ្នាំប៉ុន្មានលើក? អ្វីខ្លះ?

២-តើអ្វីទៅជាផែនការក្រាំឆ្នាំនៅសហភាពសូវៀត? ផែនការ៥ឆ្នាំលើកទី៤ ទី៥ និងទី៦ បានផ្តល់គុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះសម្រាប់សហភាពសូវៀត?

៣-សង្គមសហភាពសូវៀត

១-តើការដឹកនាំរបស់លោក ប្រេស្នែវ មានលក្ខណៈដូចម្តេច?

៤-កំណែទម្រង់ប៉េរ៉ែស្រ្តូយកា (Perestroika)

១-តើកំណែទម្រង់ប៉េរ៉ែស្រ្តូយកាជាអ្វី? តើកំណែទម្រង់ប៉េរ៉ែស្រ្តូយការបានផ្តល់ផលវិបាកអ្វីខ្លះដល់ប្រទេសនៅអឺរ៉ុប?

២-តើកំណែទម្រង់ប៉េរ៉ែស្រ្តូយកាបានធ្វើទៅលើវិស័យអ្វីខ្លះ? ចូររៀបរាប់។

៥-ការដួលរលំសហភាពសូវៀត

១-ហេតុអ្វីបានជាសហភាពសូវៀតដួលរលំ?

២-ចូរប្រៀបធៀបពីរបបនយោបាយ សេដ្ឋកិច្ច សង្គមរបស់សហរដ្ឋអាម៉េរិក និងសហភាពសូវៀតនាក្រោយសង្គ្រាមលោកលើកទី២។

៣-ហេតុអ្វីបានលទ្ធិកុម្មុយនីស្តរីកសាយយ៉ាងខ្លាំងនៅក្រោយសង្គ្រាមលោកលើកទី២?

មេរៀនទី៣ អឺរ៉ុប និងសង្គ្រាមត្រជាក់

១-នយោបាយអឺរ៉ុបក្នុងដំណាក់កាលសង្គ្រាមត្រជាក់

១-ចូរប្រៀបធៀបពីភាពខុសគ្នានៃការគ្រប់គ្រងរដ្ឋរបស់បណ្តារដ្ឋនៅប្លុកខាងកើត និងប្លុកខាងលិច។

២-តើសង្គ្រាមត្រជាក់មានន័យដូចម្តេច? សង្គ្រាមនេះជះឥទ្ធិពលដូចម្តេចខ្លះដល់ពិភពលោក?

៣-តើបញ្ហាសង្គ្រាមត្រជាក់ ត្រូវបានគេកំណត់ថាវាកើតឡើងដោយផ្អែកលើទិដ្ឋភាពអ្វីខ្លះ?

៤-ហេតុអ្វីបានជាសង្គ្រាមត្រជាក់ចាប់ផ្តើមនៅអឺរ៉ុប?

៥-ហេតុអ្វីបានជាអាល្លឺម៉ង់ បែងចែកជាពីរ? តើប្រទេសនេះរួបរួមគ្នាវិញដោយរបៀបណា?

៦-តើមានកត្តាអ្វីខ្លះធ្វើឱ្យអាល្លឺម៉ង់អាចបង្រួបបង្រួមគ្នាឡើងវិញបាន?

៧-តើការបង្រួបបង្រួមអាល្លឺម៉ង់ធ្វើឡើងដោយផ្អែកលើគោលការណ៍អ្វីខ្លះ? គោលបំណងអ្វី?

៨-ចូររៀបរាប់ពីអង្គការណាតូ និងកតិកាសញ្ញាវ៉ាសូវី។

៩-ចូរបង្ហាញពីនយោបាយក្រៅប្រទេសរបស់ប្រធានាធិបតីបារាំង លោក សាលដឺហ្គោល។

១០-ហេតុអ្វីបានជានៅចន្លោះឆ្នាំ ១៩៦៣-១៩៦៨ សង្គ្រាមត្រជាក់ចាប់ផ្តើមមានភាពធូរស្រាលឡើងវិញ?

១១-តើសន្តិសហវិជ្ជមានជាអ្វី?

១២-ហេតុអ្វីបានជាក្រោយសង្គ្រាមលោកលើកទី២ ទ្វីបអឺរ៉ុបបែងចែកជាពីរប្លុក?

១៣-ចូរពណ៌នាពីមូលហេតុនៃការដួលរលំប្រទេសអឺរ៉ុបខាងកើតនាចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ និងការបង្កើតពិភពលោកឯកប៉ូល?

១៤-ចូរបង្ហាញពីការប្រឈមមុខដាក់គ្នារវាងសហរដ្ឋអាម៉េរិក និងសហភាពសូវៀតជុំវិញបញ្ហាអាល្លឺម៉ង់។

២-ការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចអឺរ៉ុប

១-តើអ្វីទៅជាផែនការម៉ាសាល?

២-តើផែនការម៉ាសាលបានជួយស្តារសេដ្ឋកិច្ចអឺរ៉ុបខាងលិចបានយ៉ាងដូចម្តេច?

៣-តើកិច្ចសហការសេដ្ឋកិច្ចនៅអឺរ៉ុបខាងលិចបានជួយអឺរ៉ុបឱ្យមានការរីកចម្រើនយ៉ាងដូចម្តេច?

៤-ហេតុអ្វីបានជាបារាំងប្រើសិទ្ធិវេតូមិនឱ្យអង់គ្លេសចូលជាសមាជិកផ្សារួមអឺរ៉ុប?

៥-តើអង់គ្លេសបានចូលជាសមាជិកផ្សារួមអឺរ៉ុបនៅថ្ងៃខែឆ្នាំណា? ព្រោះអ្វី?

៦-ចូររៀបរាប់ពីស្ថានភាពសេដ្ឋកិច្ចនៅអឺរ៉ុបខាងកើត។

៣-សង្គមនៅអឺរ៉ុប

១-ចូររៀបរាប់ពីស្ថានភាពសង្គមនៅអឺរ៉ុបខាងកើត។

២-តើរដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់បានយកចិត្តទុកដាក់ចំពោះសង្គមយ៉ាងដូចម្តេច?

៣-ចូរប្រៀបធៀបអំពីរបបនយោបាយ សេដ្ឋកិច្ច សង្គម របស់អាល្លឺម៉ង់ខាងកើត និងអាល្លឺម៉ង់ខាងលិច។

មេរៀនទី៤ ប្រទេសចិន និងសង្គ្រាមត្រជាក់

១-ស្ថានភាពប្រទេសចិនមុនសង្គ្រាមលោកលើកទី២

១-តើមុនសង្គ្រាមលោកលើកទី២ ប្រទេសចិនស្ថិតក្នុងស្ថានភាពដូចម្តេច?

២-ស្ថានភាពប្រទេសចិនក្នុងសង្គ្រាមលោកលើកទី២

១-តើក្នុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៤៦-១៩៤៩ មានភាគីជម្លោះណាខ្លះ? ហើយលទ្ធផលដូចម្តេច?

៣-ប្រទេសចិនក្នុងដំណាក់កាលសង្គ្រាមត្រជាក់

១-តើក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្ត ប្រទេសចិនមានស្ថានភាពដូចម្តេច?

២-តើនយោបាយមហាលោតផ្លោះអ្វី? មានគោលដៅដូចម្តេច?

៣-តើផែនការមហាលោតផ្លោះបានទទួលជោគជ័យដែរឬទេ? ព្រោះអ្វី?

៤-តើបដិវត្តន៍វប្បធម៌ជាអ្វី? បង្កើតឡើងក្នុងគោលបំណងអ្វី? ទទួលបានលទ្ធផលដូចម្តេច?

៥-ហេតុអ្វីបានជាកុម្មុយនីស្តចិន មានភាពប្រេះឆាជាមួយសហភាពសូវៀត?

៦-ហេតុអ្វីបានជាមានការខិតជិតគ្នារវាងចិនកុម្មុយនីស្តជាមួយសហរដ្ឋអាម៉េរិក?

៧-ហេតុអ្វីបានជានៅឆ្នាំ១៩៧១ អង្គការសហប្រជាជាតិបានបោះឆ្នោតដកកៅអីពីតៃវ៉ាន់ ហើយប្រគល់សិទ្ធិឱ្យរដ្ឋាភិបាលប៉េកាំងវិញ?

៤-ប្រទេសចិនក្នុងដំណាក់កាលកំណែទម្រង់

១-ចូររៀបរាប់ពីកម្មវិធីកំណែទម្រង់សំខាន់ៗរបស់លោក តេង ស៊ាវពីង។

២-តើនយោបាយទំនើបកម្ម៤បែបរបស់លោក តេង ស៊ាវពីង មានអ្វីខ្លះ?

៥-ស្ថានភាពសេដ្ឋកិច្ច សង្គម

១-ចូររៀបរាប់ពីស្ថានភាពសេដ្ឋកិច្ចចិននៅក្រោយសង្គ្រាមត្រជាក់-ស.វទី២០។

២-ចូររៀបរាប់ពីស្ថានភាពសង្គមចិននៅក្រោយសង្គ្រាមត្រជាក់។

៣-តើសាធារណរដ្ឋប្រជាមានិតមានស្ថាប័នជាតិសំខាន់ៗប៉ុន្មាន? អ្វីខ្លះ?

៤-តើប្រធានាធិបតីចិនបច្ចុប្បន្នមានឈ្មោះអ្វី? មានតួនាទីអ្វីខ្លះ?

៥-តើប្រទេសចិនចែកប្រព័ន្ធតុលាការជាប៉ុន្មានកម្រិត? អ្វីខ្លះ? ចូររៀបរាប់។

៦-ចូររៀបរាប់ពីទំនាក់ទំនងរវាងកម្ពុជា-ចិន។

រៀបរៀងដោយ ឈិន ចណ្ឌី

មេរៀនទី៥ ចលនាមិនចូលបក្សសម្ព័ន្ធ

១-ការបង្កើត និងគោលបំណង

១-តើចលនាមិនចូលបក្សសម្ព័ន្ធត្រូវបានបង្កើតឡើងនៅថ្ងៃខែឆ្នាំណា? នៅឯណា?

២-តើចលនាមិនចូលបក្សសម្ព័ន្ធជាអ្វី? មានប្រទេសណាខ្លះ?

៣-តើកត្តាអ្វីខ្លះបណ្តាលកើតមានចលនាមិនចូលបក្សសម្ព័ន្ធ?

៤-តើចលនាមិនចូលបក្សសម្ព័ន្ធបង្កើតឡើងក្រោមការផ្តួចផ្តើមរបស់មេដឹកនាំរូបណាខ្លះ?

៥-តើសន្និសីទលើកទី១ នៃចលនាមិនចូលបក្សសម្ព័ន្ធបានធ្វើឡើងនៅទីណា? ឆ្នាំណា? បានអនុម័តសេចក្តីថ្លែងការណ៍សំខាន់ៗអ្វីខ្លះ?

៦-តើចលនាមិនចូលបក្សសម្ព័ន្ធបង្កើតក្នុងគោលបំណងអ្វី?

២-រចនាសម្ព័ន្ធ និងគោលការណ៍

១-តើរចនាសម្ព័ន្ធដឹកនាំចលនាមិនចូលបក្សសម្ព័ន្ធត្រូវធ្វើឡើងដូចម្តេច?

២-ដើម្បីចូលជាសមាជិកចលនាមិនចូលបក្សសម្ព័ន្ធ រដ្ឋសុំបេក្ខភាពត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?

៣-តើគោលការណ៍បញ្ចសីលានៃចលនាមិនចូលបក្សសម្ព័ន្ធមានអ្វីខ្លះ?

៣-ដំណាក់កាលសង្គ្រាមត្រជាក់

១-តើនៅក្នុងដំណាក់កាលសង្គ្រាមត្រជាក់ចលនាមិនចូលបក្សសម្ព័ន្ធបានធ្វើសកម្មភាពអ្វីខ្លះ?

៤-ដំណាក់កាលក្រោយសង្គ្រាមត្រជាក់

១-ក្រោយសង្គ្រាមត្រជាក់ចលនាមិនចូលបក្សសម្ព័ន្ធជួបប្រទះនឹងបញ្ហាអ្វីខ្លះ?

២-ចូររៀបរាប់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃចលនាមិនចូលបក្សសម្ព័ន្ធ?

មេរៀនទី៦ បញ្ហាឯកោភាពក្នុងពិភពលោក

១-បញ្ហាបរិស្ថាន

១-តើមានបាតុភូតអ្វីខ្លះដែលបង្កឱ្យមានបញ្ហាដល់បរិស្ថាន?

២-តើការខូចបរិស្ថាន បម្រែបម្រួលអាកាសធាតុ បាត់បង់ព្រៃឈើ នាំឱ្យមានផលប៉ះពាល់អ្វីខ្លះ?

៣-គេថា «បញ្ហាបរិស្ថានកើតសកម្មភាពរបស់មនុស្ស» ចូរបកស្រាយ។

៤-ដើម្បីស្តារបរិស្ថានឡើងវិញ តើគេត្រូវមានវិធានការដូចម្តេចខ្លះ?

៥-តើព្រៃឈើមានសារៈសំខាន់ដូចម្តេចខ្លះ?

២-បញ្ហាកំណើនប្រជាជន និងបញ្ហាជនអន្តោប្រវេសន៍

១-តើកំណើនប្រជាជនចោទជាបញ្ហាអ្វីខ្លះ?

២-តើរដ្ឋាភិបាលនីមួយៗចាត់វិធានការយ៉ាងដូចម្តេចខ្លះ ដើម្បីដោះស្រាយបញ្ហាកំណើនប្រជាជន?

៣-បញ្ហាសន្តិសុខស្បៀង

១-ចូរពណ៌នាពីបញ្ហាសន្តិសុខស្បៀងជាបញ្ហាប្រឈមដែលពិភពលោកកំពុងជួបប្រទះ និងវិភាគពីកត្តាសំខាន់ៗដែលធ្វើឱ្យកម្ពុជាសម្រេចបានសន្តិសុខស្បៀង។

២-តើគេធ្លាប់បានដោះស្រាយបញ្ហាកង្វះស្បៀងនាពាក់កណ្តាលទសវត្សឆ្នាំ ១៩៧០ដោយរបៀបណា?

៣-តើរដ្ឋាភិបាលនានា និងអ្នកវិទ្យាសាស្ត្រធ្វើដូចម្តេចខ្លះ ដើម្បីដោះស្រាយបញ្ហាកង្វះស្បៀង? ចំណាត់ការនោះទទួលបានលទ្ធផលយ៉ាងណា?

៤-បញ្ហាសង្គ្រាម និងអស្ថិរភាពសន្តិសុខសង្គម

១-តើនៅមុនសង្គ្រាមត្រជាក់ពិភពលោកប្រឈមមុខនឹងសង្គ្រាមលោកប៉ុន្មានលើក? សង្គ្រាមទាំងនេះនាំមកនូវផលវិបាកអ្វីខ្លះដល់មនុស្សជាតិ?

២-តើសង្គ្រាមត្រជាក់បាននាំមកនូវអស្ថិរភាពដូចម្តេចខ្លះ ចំពោះសន្តិសុខសង្គម?

៣-តើមានបញ្ហាអ្វីខ្លះ នាំមកនូវអស្ថិរភាពចំពោះសន្តិសុខសង្គមទូទៅលើពិភពលោកក្រោយសង្គ្រាមត្រជាក់? ពិភពលោករួមគ្នាដោះស្រាយយ៉ាងដូចម្តេចខ្លះ?

៥-បញ្ហាការរីករាលដាលនៃជំងឺឆ្លង

១-តើប្រភពជំងឺកូវីដ-១៩ ត្រូវបានគេរកឃើញដំបូងនៅឆ្នាំណា? ប្រទេសណា? ការរីករាលដាលនៃជំងឺនេះ បានផ្តល់ផលវិបាកអ្វីខ្លះដល់ពិភពលោក?

៦-មូលហេតុចម្បងនៃការលេងឡើងនូវបញ្ហារួមលើពិភពលោក

១-តើពិភពលោកកំពុងប្រឈមនឹងបញ្ហាធំៗអ្វីខ្លះនៅពេលបច្ចុប្បន្ន?

២-ចូររៀបរាប់ពីប្រភពមូលដ្ឋានដែលនាំឱ្យលេចឡើងនូវបញ្ហារួមនៅលើពិភពលោក។

៣-ហេតុអ្វីបានជារាល់បញ្ហារួមលើពិភពលោក ទាមទារឱ្យមានការចូលរួមដោះស្រាយ?

មេរៀនទី៧ ដំណើរវិវឌ្ឍសកលភាវូបនីយកម្ម

១-មូលហេតុនៃសកលភាវូបនីយកម្ម

១-តើអ្វីជាសកលភាវូបនីយកម្ម?

២-ចូរពណ៌នាពីមូលហេតុ និងផលវិបាកនៃសកលភាវូបនីយកម្ម។

៣-តើមានអង្គការណាខ្លះដែលបានធ្វើសកម្មភាពសមាហរណកម្មសកលលោក?

៤-ដូចម្តេចដែលហៅថា ប្រទេសG8 ? មានប្រទេសណាខ្លះ?

៥-តើប្រទេស G20 ជាអ្វី? មានប្រទេសណាខ្លះ? មានទិសដៅដូចម្តេច?

៦-ហេតុអ្វីគេចាត់ទុកសហគមន៍អឺរ៉ុបជាសហគមន៍មួយដែលទទួលបានជោគជ័យជាងគេ?

៧-តើនៅលើពិភពលោកមានទស្សនៈសកលភាវូបនីយកម្មប៉ុន្មាន? អ្វីខ្លះ?

៨-តើទិសដៅនយោបាយពិតប្រាកដនៃសកលភាវូបនីយកម្មមានអ្វីខ្លះ?

២-ការវិវត្តសកលភាវូបនីយកម្ម

១-ដូចម្តេចដែលហៅថារដ្ឋ? តើរដ្ឋមានធាតុសំខាន់ៗអ្វីខ្លះ?
២-តើអធិបតេយ្យភាពរបស់រដ្ឋមានន័យដូចម្តេច?
៣-ដូចម្តេចដែលហៅថា ប្រជាជាតិ?
២-តើការវិវត្តនៃសកលភាវូបនីយកម្ម បានធ្វើឱ្យតួនាទីអធិបតេយ្យភាពរបស់រដ្ឋ ប្រែប្រួលដូចម្តេចខ្លះ?
៣-តើប្រទេសតតិយលោកធ្វើដូចម្តេចខ្លះ ដើម្បីបញ្ចៀសនូវការលូកដៃពីសំណាក់មហាអំណាច?
៤-ចូរបង្ហាញពីការកសាងលទ្ធិប្រជាធិបតេយ្យនៅតាមប្រទេសទន់ខ្សោយ និងលទ្ធផល។
៥-តើគេត្រូវធ្វើដូចម្តេច ដើម្បីកសាងសង្គមប្រជាធិបតេយ្យឱ្យបានរឹងមាំ?
៦-ហេតុអ្វីបានជាប្រទេសដែលទើបតែចាកផុតពីរបបកុម្មុយនីស្ត អនុវត្តលទ្ធិប្រជាធិបតេយ្យពុំទាន់បានរឹងមាំ?
៧-តើពិភពលោកពហុជាតិមានន័យដូចម្តេច?
៨-ចូរពណ៌នាពីតួនាទីរបស់រដ្ឋនៅក្នុងដំណើរវិវត្តសកលភាវូបនីយកម្ម។
៩-តើយោធាមានតួនាទីដូចម្តេចខ្លះ នៅក្នុងចរន្តសកលភាវូបនីយកម្ម?

ផែនទីសំណួរក្នុងសៀវភៅនេះ
ចប់ដោយសង្ខេប



ទំនាក់ទំនងទិញតាមរយៈ:

ឈិន ចណ្ឌី



មានលក់សៀវភៅជំនួយស្មារតី

ប្រវត្តិវិទ្យា ថ្នាក់ទី៧-១២

ស្របតាមកម្មវិធីសិក្សាថ្មី

ទំនាក់ទំនងតាមរយៈ